**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៦៩

ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២

**សាលដីកា**

លេខ ៣៨៥ VIII

ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២

# សាលដីកា

# តាងនាមប្រជារាស្ត្រខ្មែរ

# តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ ដោយអង្គជំនុំជម្រះដែលមានសមាសភាពដូចខាងក្រោម៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-ឯកឧត្តម [redacted] ជាចៅក្រមរបាយការណ៍

៣-ឯកឧត្តម [redacted] ជាចៅក្រម

៤-ឯកឧត្តម [redacted] ជាចៅក្រម

៥-ឯកឧត្តម [redacted] ជាចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

ឯកឧត្តម [redacted] ឋានៈជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្ដឹងសាទុក្ខលេខ ២៦០ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ របស់អគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ២៥ “ក្រ III ឧ.រ” ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន៖

- **បុគ្គលប្ដឹងសាទុក្ខ គឺអគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ**

- ជនត្រូវចោទឈ្មោះ [redacted] សារ៉េត ហៅ [redacted] សារិន ភេទប្រុស ឆ្នាំកំណើត១៩៥៧ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរគ្មានដេរី មានទីកន្លែងកំណើតនៅភូមិបុណ្ណា ឃុំព្រះពុទ្ធ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ទីលំនៅមុនពេល [redacted] ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។ ឪពុកឈ្មោះ [redacted]

"ស្លាប់" ម្ដាយឈ្មោះ [redacted] ស្លាប់" ប្រពន្ធឈ្មោះ [redacted] "រស់" មានកូនចំនួន ០២នាក់ ជានីតិជនទោសពីមុនមានទ្វេពន្ធភាព (អំពើផិតក្បត់) និងក្លែងស័ក្ដិឧត្ដមសេនីយ៍ទោ ។

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ២៥៤/០២២ ដ.ក ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃតុលាការយោធា នៅមន្ទីរពន្ធនាគារអយ្យការអមតុលាការយោធា។

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ **ក្លែងបន្លំឯកសារសាធារណៈ** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ ។

មេធាវីការពារសិទ្ធិលោក [redacted] **ណារ៉ា** ។

- **ដើមបណ្ដឹងរដ្ឋប្បវេណី** ក្រសួងការពារជាតិ តំណាងដោយមេធាវី [redacted] **ចេតនា** មេធាវី [redacted] **ពិសិដ្ឋរង្សី** មេធាវី [redacted] **សុជាតិ** និងមេធាវី [redacted] **សុជាតិ** ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ មានករណីប្រើប្រាស់ឯកសារសាធារណៈក្លែងលិខិត ៩៧១៦/២០២២ ស.ណ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ របស់ឧបនាយករដ្ឋមន្ត្រី មន្ត្រីក្រសួងការពារជាតិ ដែលឈ្មោះ [redacted] សូត្រវិចិត្រ ប្រើឱ្យឈ្មោះ [redacted] សុផានី យកលិខិតនោះទៅជួបឈ្មោះ [redacted] ស៊ុយហាក់ ដោយពេលនោះ ឈ្មោះ [redacted] ស៊ុយហាក់ ពិនិត្យទៅឃើញថាមានភាពមិនប្រក្រតីទាំងទម្រង់ និងខុសអក្ខរាវិរុទ្ធច្រើនទើបគេតម្រូវឱ្យធ្វើសាជាថ្មីម្ដងទៀត។ លុះក្រោយមកឈ្មោះ [redacted] សូត្រវិចិត្រ បានយកលិខិតលេខ ៩១៦៨/០២២ ស.ណ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ប្រើឱ្យឈ្មោះ [redacted] សុផានី យកទៅជួបឈ្មោះ [redacted] ស៊ុយហាក់ ដើម្បីពិនិត្យឡើងវិញ ដោយមើលឃើញថា លិខិតនោះនៅតែមិនទំនង រូបគេក៏ដកថយមកគិតមើលសិន ក្រោយមកទើបគេទូរស័ព្ទទៅឈ្មោះ [redacted] សុផានី ថាសុំឆែកនៅសាមីក្រសួងសិន ហើយឈ្មោះ [redacted] សុផានី បានទូរស័ព្ទប្រាប់ទៅ [redacted] សូត្រវិចិត្រ គេតបថាឱ្យគាត់ឆែកចុះ ដោយប្រាប់ទាំងឈ្មោះ និងលេខទូរស័ព្ទអ្នកធ្វើលិខិតនេះទៀតផង គឺឈ្មោះ [redacted] សារិន ប្រើទូរស័ព្ទលេខ [redacted] ទើបឈ្មោះ [redacted] ស៊ុយហាក់ យកលិខិតនោះឱ្យមេធាវីជួយឆែកនៅក្រសួងការពារជាតិ ទើបដឹងច្បាស់ថាលិខិតនោះក្លែងក្លាយ។ ក្រោយមកសមត្ថកិច្ចបានធ្វើការស្រាវជ្រាវ និងសាកសួរទៅលើបុគ្គលដែលពាក់ព័ន្ធរួចមកនៅចំពោះសមត្ថកិច្ចជនសង្ស័យឈ្មោះ [redacted] សូត្រវិចិត្រ ភេទប្រុស បានឆ្លើយសារភាពថា ឯកសណ្ឋានយោធា និងសក្ដិផ្កាយពីរព្រមទាំងលិខិតលេខ ៩៧១៦/២០២០ ស.ណ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ និងលេខ ៩១៦៨/២០២២ ស.ណ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ របស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ គឺខ្លួនគេទទួលបានពីឈ្មោះ [redacted] សារិន និង [redacted] ស៊ីហារ៉ា ភេទប្រុស។ ចំពោះសកម្មភាពនៃការប្រព្រឹត្ត

នូវអំពើល្មើសខាងលើ គឺក្រុមរបស់ជនសង្ស័យមានគ្នាចំនួន ០៣នាក់ ដែលមានឈ្មោះ [redacted] សារិន និងឈ្មោះ [redacted] ហៅវ៉ា ជាមេក្លោង រួមទាំងឈ្មោះ [redacted] សូត្រវិចិត្រ ព្រមទាំងបក្សពួកគូរកនផ្សេងទៀត ។

- **បានឃើញ** ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសាន្នលេខ ២៥៣/០២២ ដ.ក ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃតុលាការឃោធា ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

ឱ្យឃុំខ្លួនជនត្រូវចោទឈ្មោះ [redacted] សារ៉េត ហៅ [redacted] សារិន ភេទប្រុស ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ជាបណ្ដោះអាសន្ន ដែលយើងនឹងបង្គាប់ឱ្យឃុំខ្លួនជននេះតាមអំណាចដីកាបង្គាប់ឱ្យឃុំខ្លួន។

- **បានឃើញ** សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ ២៦២ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ របស់ជនត្រូវចោទឈ្មោះ [redacted] សារ៉េត ហៅ [redacted] សារិន ដែលប្ដឹងមិនសុខចិត្តនឹងដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ២៥៣/០២២ ដ.ក ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃតុលាការឃោធា។

- **បានឃើញ** សាលដីកាព្រហ្មទណ្ឌលេខ ២៥ "ក្រ III ឧ.រ" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១. ទទួលបណ្ដឹងឧទ្ធរណ៍លេខ ២៦២ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២ របស់ជនត្រូវចោទឈ្មោះ [redacted] សារ៉េត ហៅ [redacted] សារិន ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយផ្អែកនឹងគតិច្បាប់ ។

២. តម្កល់ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ២៥៣/០២២ ដ.ក ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃតុលាការឃោធា ដដែល ។

សាលដីកានេះពិភាក្សាដេញដោលជាអសាធារណៈ និងប្រកាសជាអសាធារណៈ ថ្ងៃអង្គារ ៩រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ ។

- **បានឃើញ** បណ្ដឹងសាទុក្ខលេខ ២៦០ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ របស់អគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ក្នុងការប្ដឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ២៥ "ក្រ III ឧ.រ" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានឡើងធ្វើសេចក្ដីរាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្ដីសន្និដ្ឋានថា៖ សភាស៊ើបសួរសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំដោយសំអាងថាជាបទឧក្រិដ្ឋ ហើយតម្កល់ដីកាសម្រេចមិនអនុញ្ញាតឱ្យនៅក្រៅឃុំរបស់ចៅក្រមស៊ើបសួរនៃតុលាការយោធា។ រឿងក្ដីនេះមិនមែនជាសមត្ថកិច្ចរបស់តុលាការយោធាទេ គឺជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌសាមញ្ញ ហើយអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ប្ដឹងសាទុក្ខអំពីដែនសមត្ថកិច្ចដែលត្រូវចាត់ការ។ ដូចនេះសុំក្រុមប្រឹក្សាពិនិត្យ និងសម្រេចតាមច្បាប់។

ហេតុដូច្នេះ តំណាងមហាអយ្យការប្ដឹងសុំតម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២៥ "ក្រ III ឧ.រ" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការ ហើយបង្វិលរឿងនេះទៅតុលាការព្រហ្មទណ្ឌជាសមត្ថកិច្ចវិញ។

+លោក[redacted] **ណារ៉ា** ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ[redacted]**ារ៉េត** បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ការស្នើសុំនៅក្រៅឃុំរបស់កូនក្ដីខ្លួនមានមូលហេតុត្រឹមត្រូវពាក់ព័ន្ធនឹងឈ្មោះវិញ កូនក្ដីខ្លួនមានឈ្មោះ [redacted] សារ៉េត ពុំមែនឈ្មោះ[redacted] សារិន ទេ ។ ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការរួច ខ្លួនសូមបដិសេធដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នលើកូនក្ដីខ្លួន។

+ជនត្រូវចោទឈ្មោះ [redacted] **សារ៉េត** បានឆ្លើយថា ខ្លួនសូមឯកភាពតាមសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យខ្លួនទាំងស្រុង។

+លោ[redacted] **ចេតនា** ជាមេធាវីតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ក្រសួងការពារជាតិ បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ការឃុំខ្លួនជនត្រូវចោទដើម្បីរក្សាបង្ការកុំឱ្យមានបទល្មើសកើតឡើងជាថ្មី ព្រោះរឿងនេះជាបទល្មើសឧក្រិដ្ឋ ដោយសារជនត្រូវចោទធ្លាប់ប្រព្រឹត្តបទល្មើសពីមុន ខ្លួនសូមឱ្យតុលាការយោធាជាដែនសមត្ថ-កិច្ចក្នុងរឿងនេះដដែល។

**សំណូមពរ** សូមតុលាការតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ចម្លើយរបស់ជនត្រូវចោទ និងស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ និងសេចក្ដីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៦០ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ របស់អគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងក្តីនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ , មាត្រា ៤១៧, មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា មូលហេតុនៃបណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញបានសន្និដ្ឋានថា សមត្ថកិច្ចនៃរឿងក្តីនេះជាសមត្ថកិច្ចរបស់សាលាដំបូង ពុំមែនជាសមត្ថកិច្ចរបស់តុលាការយោធានោះទេ ពីព្រោះថា បទល្មើសនេះពុំមែនជាបទល្មើសយោធាទេ នោះតុលាការកំពូលពិចារណាឃើញថា បណ្តឹងសាទុក្ខលើកឡើងតែពីការសុំនៅក្រៅឃុំបណ្តោះអាសន្នតែប៉ុណ្ណោះ ដែលមិនគប្បីពន្លាតទៅដល់សមត្ថកិច្ចនោះទេ។ ដូច្នេះ បណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ ពុំមានមូលហេតុស្របតាម មាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។

៣-យល់ឃើញថា ជនត្រូវចោទឈ្មោះ[redacted]សារ៉េត ពុំបានប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ២៥ "ក្រ III ឧ.រ" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញទេ ដូច្នេះ តុលាការកំពូលមិនពិចារណាអំពីមូលហេតុនៃការឃុំខ្លួននោះទេ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២៥ "ក្រ III ឧ.រ" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១. បដិសេធបណ្តឹងសាទុក្ខលេខ ២៦០ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ របស់អគ្គព្រះរាជអាជ្ញារងនៃមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

២. តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២៥ "ក្រ III ឧ.រ" ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២ និងប្រកាសសាលដីកាជាសាធារណៈនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២២។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ជាប្រធាន |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| ឯកឧត្តម | [redacted] | ជាចៅក្រម |
| លោកស្រី | [redacted] | ជាក្រឡាបញ្ជី |

---

**បានចម្លងត្រឹមត្រូវតាមសាលដីកាដើម ។**

ថ្ងៃសុក្រ ៧កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

ថ្ងៃសុក្រ ៧កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២២

**ប្រធានអង្គជំនុំជម្រះ**

[redacted]